# តើពាណិជ្ជកម្មសេរីជួយជំរុញការរីកចំរើនដែរទេ?

*បណ្ឌិត សុខ ស៊ីណា ព្យាយាមទាក់ទាញការយកចិត្តទុកដាក់ចំពោះមតិថា ពាណិជ្ជកម្មសេរីមិនមែនជាឱសថទិព្វ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះទេ ដោយបានវែកញែកពីទ្រឹស្ដីជាច្រើនដើម្បីធ្វើការបញ្ជាក់អះអាង ។ នៅពេលកម្ពុជាឈានជើងចូលទៅក្នុងពិភពនៃសាកលភាវូបនីយកម្ម ពាណិជ្ជកម្មសេរីកំពុងដំណើរការទៅមុខជានិច្ច ហើយសមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោក* (World Trade Organisation: WTO) *ត្រូវតែប្រកួតប្រជែងគ្នា ។ ផលចំណេញ និងការខាតបង់ អាចកើតមានឡើងក្នុងពេលជាមួយគ្នា រីឯលទ្ធផលវាអាស្រ័យជាសំខាន់ទៅតាមស្ថានភាពប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ។**

សាកលភាវូបនីយកម្ម[១] និងការបារម្ភពីភាពក្រីក្រនិងវិសមភាព បានក្លាយជាបញ្ហាមានការពិភាក្សាច្រើនបំផុតនៅក្នុងមជ្ឈដ្ឋានអ្នកសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ ។ មានការយល់ឃើញផ្សេងៗគ្នាច្រើនណាស់ ពីផលប៉ះពាល់នៃសាកលភាវូបនីយកម្ម ។ អ្នកប្រឆាំងនឹងសាកលភាវូបនីយកម្មលើកឡើងថា សាកលភាវូបនីយកម្មធ្វើឱ្យអ្នកមានកាន់តែមាន ហើយអ្នកក្រកាន់តែក្រ ចំណែកឯពួកអ្នកគាំទ្រអះអាងថា សាកលភាវូបនីយកម្ម ជួយជំរុញការរីកចំរើន ។ សូម្បីក្នុងចំណោមអ្នកសេដ្ឋកិច្ច ក៏មានការខ្វែងមតិគ្នាជាខ្លាំងអំពីផលប៉ះពាល់នៃពាណិជ្ជកម្មសេរីចំពោះសេដ្ឋកិច្ចប្រទេសមួយ ។ បើសិនគ្មានការយល់ឃើញស្របគ្នាពីផលចំណេញនៃពាណិជ្ជកម្មសេរីទេ ហេតុអ្វីបានជាប្រទេសនានានៅទូទាំងពិភពលោក រួមទាំងប្រទេសក្រីក្រផង បានសំរេចចិត្តចូលក្នុង WTO? ដូចប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀតដែរ នៅពេលចូលក្នុង WTO នៅឆ្នាំ២០០៤ កម្ពុជាសង្ឃឹមថា WTO នឹងផ្ដល់ផលចំណេញដល់វិស័យនាំចេញ ជាពិសេសផលិតកម្មសំលៀកបំពាក់ ។ ដើម្បីសំរេចគោលដៅនេះ ថ្លៃថាមពល ថ្លៃដឹកជញ្ជូន និងការិយាធិបតេយ្យ ត្រូវតែកាត់បន្ថយ ហើយការកសាងសមត្ថភាពរបស់កម្មករត្រូវតែជំរុញឡើង ។

អត្ថបទសង្ខេបនេះ ពិនិត្យមើលពីវិធីដែលកម្ពុជាអាចទាញផលចំណេញពីភាពជាសមាជិក WTO ។ ផ្នែកទី១ ពិភាក្សាពីទ្រឹស្ដីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ ហើយផ្នែកទី២ បង្ហាញពីការអះអាងជំទាស់មួយចំនួន ការវិភាគពីស្ថានភាពនៅកម្ពុជា និងអនុសាសន៍គោលនយោបាយមួយចំនួន ។

## ទ្រឹស្ដីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ

យោងតាមទ្រឹស្ដីនេះ ពាណិជ្ជកម្មគឺជាប្រភពនៃការរីកចំរើន ។ ឧត្ដមភាពដាច់ខាត និងឧត្ដមភាពប្រៀបធៀប គឺជាយន្តការសំខាន់ពីរដែលអាចបង្កឱ្យមានពាណិជ្ជកម្មអន្តរជាតិ ។ សូមពិនិត្យមើលពីវិធីដែលយន្តការទាំងពីរនេះអាចទាញយកផលចំណេញពីពាណិជ្ជកម្ម ។

*កង្វះខាតទំនិញ នាំឱ្យមានពាណិជ្ជកម្ម:* ជាទូទៅ ពាណិជ្ជកម្មរវាងប្រទេសនានា កើតឡើងនៅពេលមានប្រទេសណាមួយខ្វះខាតទំនិញ ។ ពាណិជ្ជកម្មនាំមកនូវផលចំណេញ ដោយវាជួយបំពេញការខ្វះខាតទំនិញប្រើប្រាស់ និងទំនិញវិនិយោគនៅក្នុងប្រទេសនាំចូល ។ សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលពុំមានសមត្ថភាពផលិតគ្រឿងចក្រឧស្សាហកម្មសំរាប់កែច្នៃផលិតផលកសិកម្ម ការនាំចូលគ្រឿងបរិក្ខារទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាជួយឱ្យគេអាចបង្កើតផលិតផលថ្មីៗបាន ។ នៅពេលជាមួយគ្នា ប្រទេសនាំចេញក៏អាចកាត់បន្ថយអតិរេកផលិតផលរបស់ខ្លួន ។ ផលចំណេញពីការនាំចេញ អាចយកទៅប្រើប្រាស់សំរាប់គោលដៅផ្សេងទៀតបាន ហើយរឿងនេះក៏ជួយឱ្យប្រទេសនាំចេញអាចបង្កើតផលិតផលថ្មីៗទៀតដែរ ។

*ថ្លៃដើមផលិតកម្មខុសគ្នា ក៏នាំឱ្យមានពាណិជ្ជកម្មដែរ:* ទំនិញអាចមាននៅគ្រប់ប្រទេសដែលចូលរួមធ្វើពាណិជ្ជកម្ម ប៉ុន្តែថ្លៃដើមផលិតកម្ម វាខុសគ្នា ។ តាមរយៈពាណិជ្ជកម្ម សុខមាលភាពនៅប្រទេសទាំងនោះអាចកើនឡើងតាមរយៈការកាត់បន្ថយថ្លៃដើមផលិតកម្ម ។ ប្រទេសដែលមានថ្លៃដើមផលិតកម្មខ្ពស់ អាចជំនួសផលិតផលក្នុងស្រុកដោយទំនិញនាំចូល ដែលផលិតឡើងអស់ថ្លៃដើមទាបជាង ។ ដូច្នេះពាណិជ្ជកម្មជួយឱ្យប្រទេសមួយអាចកសាងជំនាញឯកទេសនៅក្នុងវិធីសាស្ត្រផលិតរបស់ខ្លួន ។ ការរីកចំរើនក្នុងវិធីសាស្ត្រផលិត មិនត្រឹមតែកាត់បន្ថយថ្លៃដើមផលិតកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឱ្យមានផលិតផលថ្មីៗទៀតផង ។

## ការអះអាងជំទាស់

ទ្រឹស្ដីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ មានគេរិះគន់ជាយូរមកហើយ ។ លោក Friedrich List ជាសេដ្ឋវិទូដើមកំណើតអាឡឺម៉ង់ និងជាមនុស្សម្នាក់ក្នុងចំណោមស្ថាបនិកដ៏សំខាន់ៗបំផុតនៃទ្រឹស្ដីពន្ធគយ បានរិះគន់យ៉ាងខ្លាំងចំពោះការអះអាងរបស់លោក Adam Smith ដែលបានអំពាវនាវឱ្យបង្កើតពាណិជ្ជកម្មសេរីនេះឡើង ។ យោងតាម List ពាណិជ្ជកម្មអាចនាំឱ្យមានការបែងចែកស្មើគ្នានូវភាពចំរុងចំរើន គឺលុះត្រាតែបណ្ដាប្រទេសចូលរួមធ្វើពាណិជ្ជកម្មមានកំរិតអភិវឌ្ឍន៍ស្មើគ្នា បើពុំនោះទេ វានឹងនាំឱ្យមានអ្នកឈ្នះ និង អ្នកចាញ់ ។ ជាទូទៅ អ្នកឈ្នះគឺជាប្រទេសអ្នកមាន ពីព្រោះវិធីផលិតរបស់គេមានការអភិវឌ្ឍន៍ខ្ពស់ជាង ហើយអ្នកចាញ់គឺជាប្រទេសក្រីក្រ ។ ដូច្នេះ ពាណិជ្ជកម្មសេរី មិនមែនជាឱសថទិព្វសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះទេ ។

អ្នកគាំទ្រទ្រឹស្ដីនៃការពឹងផ្អែក (ឧ. Paul Baran 1975) បានជជែកវែកញែកថា ប្រទេសកំពុងអភិវឌ្ឍន៍ គួរតែផ្ដាច់ចំណងទាក់ទងជាមួយប្រទេសអភិវឌ្ឍន៍តែម្ដង ។ យោងតាមទ្រឹស្ដីនេះ ការធ្វើសមាហរណកម្មកាន់តែខ្លាំងទៅក្នុងទីផ្សារពិភពលោក អាចមានផលប៉ះពាល់មិនល្អដល់ការ អភិវឌ្ឍន៍ ហើយមូលហេតុចំបង គឺការដោះដូរមិនស្មើភាពរវាងប្រទេស អភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ។ ការវែកញែកនេះទទួលបានការគាំទ្រ ពី Dieter Senghaas (Hein ឆ្នាំ១៩៩៦) ។ យោងតាម Senghaas ប្រទេស កកើតថ្មី ត្រូវការគោលការណ៍ការពារមួយចំនួនដើម្បីជួយឧស្សាហកម្មក្មេងខ្ចី របស់គេឱ្យមានជីវិតរស់ ។ Senghaas បានជជែកវែកញែកថា អឺរ៉ុបខាងលិច មានការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺដោយសារគោលការណ៍ការពារផលិតផល ក្នុងស្រុកជាជាងដោយសារពាណិជ្ជកម្មសេរី ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍នៃបណ្ដាប្រទេសឧស្សាហកម្មថ្មី (NICs) បានបង្ហាញផ្លូវដើរប្រហាក់ប្រហែលគ្នា ។ ឧទាហរណ៍ ការជំរុញការនាំចេញ និងការ

---

* អត្ថបទនេះផ្អែកលើទ្រឹស្ដីបែបក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ មតិអះអាងជំទាស់ និងការវិភាគពីស្ថានភាពនៅកម្ពុជា ។ បណ្ឌិត សុខ ស៊ីណា ជាអ្នកស្រាវជ្រាវនៅ វបសអ ។

ផលិតទំនិញជំនួសការនាំចូល គឺជាយុទ្ធសាស្ត្រផ្សំគ្នា ដែលជួយឱ្យកូរ៉េខាងត្បូង និងតៃវ៉ាន់ ក្លាយជាប្រទេសមានជោគជ័យខ្លាំងជាងគេខាងសេដ្ឋកិច្ចនៅសតវត្សរ៍ទី២0 ហើយជោគជ័យនេះកំពុងបន្តរហូតមកដល់បច្ចុប្បន្ន ។ យុទ្ធសាស្ត្រមួយនៃគោលការណ៍ការពារផលិតផលក្នុងស្រុក គឺគេអនុញ្ញាតឱ្យមានវិនិយោគទុនបរទេសផ្ទាល់ លុះត្រាណាវាមិនគំរាមកំហែងដល់វត្តមានឧស្សាហកម្មក្មេងខ្ចីក្នុងស្រុក ។ កិច្ចការពារនេះត្រូវអនុវត្តរហូតដល់ពេលឧស្សាហកម្មក្មេងខ្ចីធំពេញរូបរាងអាចប្រកួតប្រជែងបាន ហើយបន្ទាប់មក គេដកវាចេញជាបណ្តើរៗ ដើម្បីទុកឱ្យផលិតផលក្នុងស្រុកប្រឹងប្រកួត ប្រជែងជាមួយផលិតផលបរទេស ។

យុទ្ធសាស្ត្រការពារផលិតផលក្នុងស្រុក ពឹងផ្អែកលើអន្តរាគមន៍ដ៏ខ្លាំងក្លារបស់រដ្ឋនៅក្នុងសេដ្ឋកិច្ច ដែលផ្ទុយពីទ្រឹស្តីក្លាស៊ិកនៃពាណិជ្ជកម្មអន្តរជាតិ និងផ្ទុយពីមតិទូទៅរបស់អ្នកធ្វើនយោបាយរូបិយវត្ថុដែលលើកថា អន្តរាគមន៍ខ្លាំងៗរបស់រដ្ឋ ហុចផលមិនល្អទេដល់កំណើនសេដ្ឋកិច្ច ។ ប៉ុន្តែ ពួកអ្នកគាំទ្រទ្រឹស្តីពន្ធគយបានជជែកវែកញែកថា គោលការណ៍ការពារផលិតផលក្នុងស្រុកនេះ គ្មានបង្កគ្រោះថ្នាក់អ្វីទេ ប៉ុន្តែគឺកង្វះចំណុចផ្តោតនៃគោលការណ៍ការពារ និងការយឺតយ៉ាវក្នុងការកំណត់ពីផលប៉ះពាល់អវិជ្ជមាននៃគោលការណ៍ការពារទៅវិញទេ ដែលបង្កគ្រោះថ្នាក់នោះ ។

## ស្ថានភាពកម្ពុជា

វិធីសាស្ត្របែបទ្រឹស្តីដូចពិភាក្សានៅខាងលើ ជួយផ្តល់គំនិតយ៉ាងច្បាស់ថា ពាណិជ្ជកម្មសេរីមិនមែនសុទ្ធតែធានាបាននូវការរីកចំរើននោះទេ ។ ស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក កម្ពុជាបានចូលជាសមាជិក WTO នៅខែកញ្ញា ឆ្នាំ២00៤ ហើយការណ៍នេះបង្ហាញពីកិច្ចខិតខំរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈពាណិជ្ជកម្ម ដែលចាត់ទុកជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយ ដើម្បីបង្កើនការងារនៅគ្រប់វិស័យ ។ ទោះបីពាណិជ្ជកម្មបានកើនឡើងយ៉ាងខ្លាំងតាំងពីពេលបង្កើតរដ្ឋាភិបាលចំរុះនៅឆ្នាំ១៩៩៣ មកក្តី ក៏ពាណិជ្ជកម្មក្រៅប្រទេស បានពឹងផ្អែកយ៉ាងខ្លាំងតែទៅលើវិស័យមួយ គឺឧស្សាហកម្មកាត់ដេរ ។ ឧទាហរណ៍ ការនាំចេញផលិតផលសំលៀកបំពាក់[២] មានរហូតដល់ ៧0% នៃការនាំចេញសរុបនៅឆ្នាំ ១៩៩៨-២00២ ដោយកើនពី ២0លានដុល្លារនៅឆ្នាំ១៩៩៥ ដល់ជិត ២ពាន់លានដុល្លារ នៅឆ្នាំ២00៤ ។

កំណើនក្នុងឧស្សាហកម្មកាត់ដេរ ផុសចេញពីកត្តា ៣ជាសំខាន់: (១) ច្បាប់វិនិយោគទុនផ្ទាល់ (២) ផលចំណេញបានពីលក្ខខណ្ឌពាណិជ្ជកម្មអនុគ្រោះបំផុត (MFN) និងប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលផ្តល់ឱ្យដោយសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និង (៣) កំលាំងពលកម្មថោក ។ ឧស្សាហកម្មនាំចេញរបស់កម្ពុជា បានស្ទុះឡើងនៅចំពេលគេធ្វើឱ្យមានសេរីភាវូបនីយកម្មលើពាណិជ្ជកម្មសំលៀកបំពាក់ ដែលត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងវិស័យកាត់ដេរ និងវាយនភ័ណ្ឌ ។ នៅក្នុងព្រមព្រៀងនេះ ពាណិជ្ជកម្មផលិតផលសំលៀកបំពាក់ វាអាស្រ័យទៅតាមកិច្ចព្រមព្រៀងទ្វេភាគី ។ កូតា និងពន្ធនាំចូល គឺកំណត់ដោយប្រទេសនាំចូល ។ កិច្ចព្រមព្រៀងវិស័យកាត់ដេរនិងវាយនភ័ណ្ឌ បានបញ្ចប់នៅចុងឆ្នាំ២00៤ ហើយតាំងពីនោះមក ពុំមានកូតាសំរាប់ពាណិជ្ជកម្មផលិតផលសំលៀកបំពាក់ចំពោះសមាជិក WTO ទៀតទេ ។ ការនាំចេញនិងនាំចូលផលិតផលសំលៀកបំពាក់ ពុំមានការរឹតបន្តឹងទៀតទេ ហើយវាស្ថិតក្រោមអត្រាពន្ធគយធម្មតា ។ ដើម្បីឱ្យឧស្សាហកម្មកាត់ដេរមានដំណើរការ កម្ពុជាត្រូវការសមាជិកភាពក្នុង WTO ។ នេះជាការវែកញែកសមហេតុផលមួយ ។ ប៉ុន្តែពាណិជ្ជកម្មសេរីមានន័យថា ផលិតផលក្នុងស្រុក ត្រូវប្រកួតប្រជែងជាមួយផលិតផលបរទេស ទាំងនៅលើទីផ្សារពិភពលោក និងទីផ្សារក្នុងស្រុក ។

ផលចំណេញពិត និងការខាតបង់ពិតនៃពាណិជ្ជកម្មសេរី សឹងតែមិនអាចគណនាកើតទេ ។ ប៉ុន្តែ គេអាចវិភាគផលប៉ះពាល់នៃពាណិជ្ជកម្មសេរីបានតាមរយៈផលប៉ះពាល់លើអ្នកប្រើប្រាស់ និងផលប៉ះពាល់លើអ្នកផលិត ។ ផលប៉ះពាល់អាចមានលក្ខណៈខុសៗគ្នា ។ បើសិនផលិតផលក្នុងស្រុកមានថ្លៃខ្ពស់ជាងផលិតផលនាំចូល តំរូវការផលិតផលនាំចូលនឹងកើនឡើង ។ ផលប៉ះពាល់លើអ្នកប្រើប្រាស់ គឺវិជ្ជមានក្នុងករណីនេះ ពីព្រោះពួកគេបានទំនិញប្រើប្រាស់ច្រើនជាងមុនក្នុងតំលៃដូចគ្នា ។ ប៉ុន្តែផលប៉ះពាល់លើអ្នកផលិត គឺអវិជ្ជមាន ពីព្រោះតំរូវការផលិតផលក្នុងស្រុកធ្លាក់ចុះ ។ ផលប៉ះពាល់វិជ្ជមានលើអ្នកប្រើប្រាស់ អាចទទួលបានដោយមានការខាតបង់ក្នុងវិស័យផលិតកម្ម ។ ដូច្នេះ កំណើនការនាំចូលអាចបណ្តាលឱ្យធ្លាក់ចុះ ចំនួនការងារធ្វើ ។ បើគិតទាំងផលប៉ះពាល់លើអ្នកផលិតផង សមាហរណកម្ម សេដ្ឋកិច្ចកម្ពុជាទៅក្នុង WTO មិនសូវភ្លឺថ្លាប៉ុន្មានទេនៅក្នុងរយៈពេលខ្លី ប៉ុន្តែ វាអាចមានលក្ខណៈវិជ្ជមាននៅក្នុងរយៈពេលវែង ។ គេត្រូវទទួលស្គាល់ថា លទ្ធផលទៅអនាគតវាជាប់ទាក់ទងនឹងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ច្រើនណាស់ ពីព្រោះអនាគតកាល គឺជារឿងបន្តពីបច្ចុប្បន្នកាល ។

ឧស្សាហកម្មកាត់ដេររបស់កម្ពុជា នៅក្មេងខ្ចីណាស់ ។ នៅចុងឆ្នាំ២00៤ ផលិតផលសំលៀកបំពាក់ជាង ៥0% បាននាំចេញទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបនៅក្រោមលក្ខខណ្ឌអនុគ្រោះ MFN រឺ GSP ។ ដោយសារលក្ខខណ្ឌអនុគ្រោះបានចប់អស់ ឧស្សាហកម្មកាត់ដេរត្រូវពឹងផ្អែកយ៉ាងខ្លាំងលើសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ។ មានកត្តាសំខាន់ៗ ៣ យ៉ាងតិចដែលកំណត់ពីលក្ខណៈប្រកួតប្រជែងរបស់សហគ្រាស ពោលគឺ ថ្លៃ គុណភាព និងជំនាញគ្រប់គ្រង ។ ទាក់ទិននឹងគុណភាពផលិតផល និងជំនាញគ្រប់គ្រងការប្រកួតប្រជែងលើទីផ្សារពិភពលោក[៣] មិនចោទបញ្ហាខ្លាំងទេ ពីព្រោះរោងចក្រកាត់ដេរប្រហែល ៨0% ជាកម្មសិទ្ធិរបស់វិនិយោគិនបរទេស ដែលភាគច្រើនមានបទពិសោធន៍ជាយូរមកហើយក្នុងមុខជំនួញនេះ ។ បញ្ហាសំខាន់សព្វថ្ងៃគឺ ថ្លៃដើមផលិតកម្ម ។ ដោយហេតុថា ចិនក៏ជាសមាជិក WTO និងស្ថិតក្នុងចំណោមប្រទេសនាំមុខគេខាងនាំចេញសំលៀកបំពាក់ ដូច្នេះកម្ពុជាត្រូវប្រឈមមុខនឹងការប្រកួតប្រជែងខ្លាំងក្លាពីប្រទេសចិន ។ ថ្លៃដើមសំលៀកបំពាក់នៅកម្ពុជា ខ្ពស់ជាងនៅចិនប្រហែល ១៥%-២0% (IMF ឆ្នាំ២00៣ ទំព័រ ៤៨) ។ ដូច្នេះ កម្ពុជាត្រូវតែបន្ទាបថ្លៃដើមផលិតកម្មរបស់ខ្លួន ឱ្យនៅត្រឹមកំរិតអាចប្រកួតប្រជែងបាន ។ ប៉ុន្តែក្នុងករណីខ្លះ គេមិនអាចបញ្ចុះថ្លៃដើមផលិតកម្មបានទេ ។ មួយចំណែកធំនៃធាតុចូលផលិតកម្មជាទំនិញនាំចូល ។ បន្ទុកចំណាយលើទំនិញទាំងនេះ មិនអាចកាត់បន្ថយនៅក្នុងស្រុកបានទេ ពីព្រោះវាអាស្រ័យលើកំរិតថ្លៃនៅទីផ្សារពិភពលោក ។ ប្រាក់បៀវត្សរ៍ប្រចាំខែអប្បបរមា ៤៥ដុល្លារ របស់កម្មកររោងចក្រកាត់ដេរ វាស្ថិតនៅខាងក្រោមកំរិតចិញ្ចឹមជីវិតគ្រាន់តែមួយរស់ (៨0ដុល្លារ) ។ ប្រាក់បៀវត្សរ៍មិនអាចកាត់បន្ថយបានទេ បើសិនចង់កាត់បន្ថយថ្លៃដើមផលិតកម្ម ។ ប៉ុន្តែមានលទ្ធភាពមួយ ដើម្បីកាត់បន្ថយថ្លៃធាតុចូលក្នុងស្រុក ។

ថ្លៃអគ្គិសនី ការដឹកជញ្ជូន និងការិយាធិបតេយ្យ ត្រូវតែកាត់បន្ថយ ។ ថ្លៃអគ្គិសនីនៅកម្ពុជា គឺ 0,១២-0,១៦ដុល្លារ/គីឡូវ៉ាត់ រឺ៤ដង ខ្ពស់ជាងនៅ

ផៃ និងវៀតណាម[៤] ។ ការដឹកជញ្ជូនកុងតឺន័រមួយទៅកាន់កំពង់ផែ ត្រូវចំណាយប្រហែល ៥០០ដុល្លារ រឺ ៤,១ដង ខ្ពស់ជាងនៅវៀតណាម[៥] ។ ចំណាយចំបងមួយទៀត ដែលឧស្សាហកម្មកាត់ដេរត្រូវប្រឈម គឺការិយាធិបតេយ្យ ។ លោក វ៉ាន់ ស៊ូ អ៊ាង[៥] ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានលើកពីផលប៉ះពាល់នៃចំណាយនេះដូចតទៅ: "ខ្ញុំសូមនិយាយម្ដងទៀត ហើយខ្ញុំហត់នឿយនឹងនិយាយដដែលៗថា ការស៊ីសំណូកការិយាធិបតេយ្យ និងអំពើពុករលួយ កំពុងរាំងស្ទះដល់ឧស្សាហកម្មកាត់ដេរ" (ឃែមបូឌាដេលី ច្បាប់ចេញថ្ងៃទី១៣ កុម្ភៈ ២០០៤ ទំព័រ១) ។

## សរុបសេចក្ដី

អង្គការ WTO នេះផ្ទាល់មិនចោទបញ្ហាអ្វីដល់កម្ពុជាទេ ប៉ុន្តែវាបង្កើតបញ្ហាប្រឈមថា តើកម្ពុជាត្រូវធ្វើយ៉ាងណាដើម្បីអាចទទួលបានផលចំណេញពីសមាជិកភាពរបស់ខ្លួន ។ រឿងនេះ តំរូវឱ្យមានការប្ដេជ្ញាចិត្តកាត់បន្ថយថ្លៃដើមផលិតកម្ម ដែលអាចធ្វើបានតាមរយៈការបង្កើនផលិតភាពនៃកំលាំងពលកម្ម និងការកាត់បន្ថយចំណាយលើការិយាធិបតេយ្យ ។ ផលិតភាពនៃកំលាំងពលកម្ម អាចបង្កើនបានតាមរយៈការប្រើប្រាស់មូលធន និងការពង្រឹងកំរិតជំនាញ ។ សមត្ថភាពដើម្បីដាក់ប្រើបច្ចេកវិទ្យាថ្មី វាអាស្រ័យទៅលើកំរិតអប់រំរបស់កម្មករ ។ ការប្រើមូលធនកាន់តែច្រើន វាជួយបង្កើនផលិតភាពកំលាំងពលកម្មក្នុងមួយរយៈដំបូង ប៉ុន្តែអាចបង្កភាពអត់ការងារធ្វើ ពីព្រោះទ្រព្យមូលធន (ម៉ាស៊ីន) អាចចូលមកជំនួសកំលាំងពលកម្ម ។ ដូច្នេះ ដើម្បីបង្កើនផលិតភាព អាទិភាពទី១ គឺកាត់បន្ថយចំណាយលើថាមពល ការដឹកជញ្ជូន និងការិយាធិបតេយ្យ ព្រមទាំងជំរុញការកសាងសមត្ថភាពកម្មករ ។ ដើម្បីសំរេចគោលដៅនេះ ត្រូវមានអន្តរាគមន៍យ៉ាងខ្លាំងក្លាពីរដ្ឋ ប៉ុន្តែវាប្រហែលត្រូវទទួលបរាជ័យ បើសិនកំណែទំរង់រដ្ឋបាលសាធារណៈគ្មានការរីកចំរើនទេនោះ ។ ដូច្នេះកម្ពុជានឹងទទួលផលចំណេញបានច្រើនប៉ុណ្ណាពីសមាជិកភាពក្នុង WTO វាស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជាខ្លួនឯង ជាពិសេសគឺការគ្រប់គ្រងរបស់រដ្ឋាភិបាល ។

## កំណត់សំគាល់

១. ពាក្យ "សាកលភាវូបនីយកម្ម" អាចយល់បានថាជាសមាហរណកម្មនៃប្រព័ន្ធសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងបរិស្ថាន ។ ពាណិជ្ជកម្មសេរីគឺជាទំរង់ពិសេសមួយនៃសមាហរណកម្មសេដ្ឋកិច្ច ។
២. មធ្យមភាគនៃការនាំចេញសំលៀកបំពាក់ ធៀបនឹងការនាំចេញសរុបនៅកំឡុងឆ្នាំ ១៩៩៨-២០០២ ។
៣. យោងតាមទិន្នន័យ ផ្ដល់ដោយគណៈកម្មាធិការវិនិយោគកម្ពុជានៅឆ្នាំ ១៩៩៩- ២០០២ ។

---

តពីទំព័រ ៤ **គួរឱ្យក្រុមប្រឹក្សាឃុំធ្វើ...**

សមត្ថភាពខាងហិរញ្ញវត្ថុនិងបច្ចេកទេសរបស់អាជ្ញាធរមូលដ្ឋានទៅទៀត ។

## កំណត់សំគាល់

១. ការចុះសិក្សាដល់កន្លែងបានធ្វើឡើងនៅ ៤ឃុំ ក្នុង ២ខេត្តគឺ ពោធិសាត់ និងសៀមរាប នៅខែឧសភា ២០០៦ និងរួមមានបទសំភាសន៍ជាមួយសមាជិកគណៈកម្មការរបស់សហគមន៍ព្រៃឈើ ក្រុមប្រឹក្សាឃុំ មន្ត្រីរដ្ឋាភិបាល បុគ្គលិក FAO SEILA និង Danida នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងតំណាងអង្គការ CONCERN និង CFR ។ ការចុះសិក្សានេះគឺជាជំហានទី១ ក្នុងគំរោងសហការស្រាវជ្រាវរវាង វិបសអ និងមជ្ឈមណ្ឌលដាណឺមាកសំរាប់ព្រៃឈើ ទេសភាព និងផែនការ ។
២. ការគ្រប់គ្រងតំបន់ការពាររបស់សហគមន៍ បានអនុវត្តនៅក្នុងឧទ្យានជាតិ និងជាការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន (Oberndorf 2005) ។

## ឯកសារយោង


Agrawal, A. and C. C. Gibson (1999), "Enchantment and disenchantment: the role of community in natural resource conservation". *World Development*, 27, pp. 629–649

Danida/DFID (2006), Natural Resource Management and Livelihoods Programme Cambodia (2006-2010). Programme Document 7 April (Cambodia: Danish Ministry of Foreign Affairs and Department for International Development).

FAO 2005. Global Forest Resources Assessment 2005, Cambodia, (Rome: Food and Agriculture Organization)

Heov K.S., B. Khlok, K. Hansen & C. Sloth (2006), "The value of forest resources to rural livelihoods in Cambodia". CDRI Policy Brief, March, issue 2

Hobley, M. (2004), Players in the sector: civil society, private sector and donor agencies. Chapter 12 (the forest sector in Cambodia, Part II. Current context. (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

Hobley, M. (ed.) (1996), "Participatory forestry: the process of change in India and Nepal". Rural development forestry study guide 3 (London: Rural Development Forestry Network, Overseas Development Institute)

Hobley, M. & M. Boscolo (2004), Policy formulation and implementation. Policy goals, regulatory control, fiscal incentives and public participation (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

IFSR (2004), The forest sector in Cambodia, Part I. Policy choices, issues and options. (Cambodia: Independent forest sector review team report commissioned by the Joint Coordinating Committee, Forest Administration).

Larson, A.M. (2003), "Decentralisation and forest Management in Latin America: Towards a Working Model", *Public Administration and Development*, 23, pp. 211–226

Marona, S., H. Kalyan & R. Kinakin (2005), "Lessons learned from CBRNM in Cambodia: drawing upon examples from case studies", Rotha, K.S., T. Carson, K. Riebe, S. Cox & E.V. Kaschke (eds.), *The Development of Community Based Natural Resource Management (CBNRM) in Cambodia. Selected Papers on Concepts and Experiences,* CBNRM Learning Initiative, CBRNM Learning Institute and WWF, Cambodia.

McKenney, B., Y. Chea, P. Tola & T. Evans (2004), *Focusing on Cambodia's High Value Forests: Livelihoods and Management* (Phnom Penh: CDRI and Wildlife Conservation Society)

Oberndorf, R. (2005), "Overview of the policy and legal framework related to CBNRM", in Rotha, K.S., T. Carson, K. Riebe, S. Cox & E.V. Kaschke (eds.), *The development of community based natural resource management (CBNRM) in Cambodia. Selected papers on concepts and experiences,* CBNRM Learning Initiative, CBRNM Learning Institute and WWF, Cambodia.

Oberndorf, R. (2004), *Law harmonisation in relation to the decentralisation process in Cambodia.* Working Paper No. 31 (Phnom Penh: Cambodia Development Resource Institute)

RGC (2003), *Sub-decree on community forestry*. (Phnom Penh: Royal Government of Cambodia).

RGC/CFO (2006). "National community forestry programme (NCFP) strategic paper". Draft strategic paper elaborated by the